# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣៣៣

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២*

## សេចក្តីជូនព័ត៌មាន

នាព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ នៅសណ្ឋាគារ កាំបូឌីយ៉ាណា, **ឯកឧត្តម វ៉ុត ឧុទ្ធី** អគ្គលេខាធិការរង គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) និង **លោកស្រី Sandra Bernklau** តំណាងនៃមូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ប្រចាំកម្ពុជា បានដឹកនាំកិច្ចប្រជុំស្តីពីការពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ២០២២ ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងមន្ត្រីមកពីទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសុខាភិបាល, ក្រសួងផែនការ, និងក្រសួងកិច្ចការនារី ។ គោលដៅចម្បងនៃកិច្ចប្រជុំគឺពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេស [Country Program Action Plan (CPAP)] ឆ្នាំ២០១៩-២០២៣ និងកំណត់អាទិភាពសម្រាប់ ឆ្នាំ២០២៣ ។

នៅឆ្នាំ២០២២ ដោយផ្អែកលើរបាយការណ៍ស្តីពីការវាយតម្លៃពាក់កណ្តាលអាណត្តិ, អង្គការ UNFPA សម្រេចបានលទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ ដូចជា÷ ១) សុខភាពបន្តពូជ និងសិទ្ធិទទួលបានសុខភាពបន្តពូជ ២) ការអប់រំក្មេងជំទង់ និងយុវជន និង ៣) ការធ្វើប្រជាសាស្ត្រ ដែលជួយគាំទ្រដល់លើកកម្ពស់សិទ្ធិក្នុងការទទួលបាននូវការថែទាំសុខភាព និងការអភិវឌ្ឍធនធានមនុស្ស ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ សកម្មភាពដែលនៅសល់នឹងបន្តអនុវត្ត និងវាយតម្លៃក្នុងឆ្នាំ២០២៣ ។

សម្រាប់ឆ្នាំ២០២៣, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងផែនការ, និងក្រសួងកិច្ចការនារីនឹងបន្តពង្រឹងសមត្ថភាពក្នុងការអនុវត្ត និងពង្រីកការផ្តល់សេវាដល់ប្រជាជន ក៏ដូចជាពិនិត្យ និងកែសម្រួលសកម្មភាពរបស់ខ្លួនឱ្យមានសង្គតិភាពនឹងអាទិភាពជាតិ ។ គួររំលឹកផងដែរ, អង្គការ UNFPA បានរៀបចំឯកសារតាម

ដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេស ដែលព្រាងដោយស្ថាប័នឯករាជ្យមួយ ក្នុងគោលបំណងផ្តល់ធាតុចូលសំខាន់ៗសម្រាប់ការរៀបចំឯកសារកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេស ឆ្នាំ២០២៤-២០២៨ ។

តាមរយៈផែនការសកម្មភាពកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេស, អង្គការ UNFPA គ្រោងវិភាជន៍ថវិកាប្រមាណ ១៣ លានដុល្លារ សម្រាប់ឆ្នាំ២០១៩-២០២៣ ឬជាមធ្យម ២.៦ លានដុល្លារ ក្នុង ០១ ឆ្នាំ ។ ក្នុងនោះ បានបើកផ្តល់ហិរញ្ញប្បទានសរុបប្រមាណ ៣.៩ លានដុល្លារ នៅឆ្នាំ២០២២ និងគ្រោងបើកផ្តល់ហិរញ្ញប្បទានប្រមាណ ២.៦ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ២០២៣ ដែលជាឆ្នាំបញ្ចប់ ។